ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...០៣...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៥/១១ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨១០ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក
- បានឃើញអនុក្រឹត្យលេខ១១៧ អនក្រ.បក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងធានាការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាពនៃតំបន់រមណីយដ្ឋានសំបូរព្រៃគុក ព្រមទាំងជំរុញការទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់វិធានក្នុងការរៀបចំនិងការគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុក។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះតំបន់រមណីយដ្ឋានសំបូរព្រៃគុក ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក និងព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៤ .-**

អាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក (អ.ជ.ស.ព.ក) ជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំនិងគ្រប់គ្រងតំបន់រមណីយដ្ឋានសំបូរព្រៃគុក។

# ជំពូកទី៣
# ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍ
## ផ្នែកទី១
## កិច្ចការបុរាណវិទ្យា

**មាត្រា៥ .-**

សកម្មភាពបុរាណវិទ្យានៅរមណីយដ្ឋានសំបូរព្រៃគុកក្នុងតំបន់ទាំង៣ **អ.ជ.ស.ព.** ត្រូវ៖

- រៀបចំកម្មវិធីលម្អិតដើម្បីស្រង់ព័ត៌មានបុរាណវត្ថុ
- ធ្វើបញ្ជីសារពើភណ្ឌស្ថានីយបុរាណ ហើយបញ្ចូលទិន្នន័យនោះទៅក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Geographic Information System)
- កំណត់លក្ខណវិនិច្ឆ័យនិងកម្មវិធីការងារសម្រាប់សម្គាល់ស្ថានីយណាដែលជាចំណុចមានគុណប្រយោជន៍ផ្នែកបុរាណវិទ្យា នរវិទ្យា ប្រវត្តិវិទ្យា ស្ថាបត្យកម្ម និងនគរូបនីយកម្ម
- កំណត់លក្ខណវិនិច្ឆ័យនិងកម្មវិធីការងារសម្រាប់សម្គាល់ទេសភាពវប្បធម៌មានលក្ខណៈបរមបុរាណដែលត្រូវការពារ
- កំណត់គោលនយោបាយដើម្បីចាត់ចែងគ្រប់គ្រងទេសភាពវប្បធម៌ទាំងនោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យានិងអប់រំ
- រៀបចំទិសដៅនិងគំរូកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយដៃគូអភិរក្ស សម្រាប់ចាត់ចែងគ្រប់គ្រងរមណីយដ្ឋាននោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យានិងអប់រំ
- រៀបចំឱ្យមានអ្នកយាមល្បាត ដើម្បីថែរក្សានិងការពារស្ថានីយបុរាណ។

**មាត្រា៦ .-**

កិច្ចការពាររមណីយដ្ឋានសំបូរព្រៃគុក **អ.ជ.ស.ព.** ត្រូវ៖

- ការពារយ៉ាងមធ្យ័តនិងទប់ស្កាត់ការរំលោភបំពានបរិវេណរមណីយដ្ឋានមានប្រាសាទក្នុងតំបន់ស្នូល ហើយគ្រប់គ្រងបរិវេណនោះសម្រាប់គោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា អប់រំ ឬលំហែកម្សាន្ត
- រៀបចំទីតាំងយុទ្ធសាស្ត្របម្រើការងារអន្តរាគមន៍បន្ទាន់សម្រាប់ជួសជុលនិងការងារអភិរក្សប្រាសាទ។

**មាត្រា៧ .-**

**អ.ជ.ស.ព.** ត្រូវ៖

- ការពារយ៉ាងមធ្យ័តនិងលើកតម្លៃសំណល់វប្បធម៌ ព្រមទាំងសំណល់ស្ថានីយបុរាណវិទ្យាទាំងអស់ដែលស្ថិតនៅលើដី ក្នុងដី និងក្នុងទឹក។ រាល់ការជីកកកាយ ជីកយកអាចម៍ដី និងការចាក់បំពេញ ឬលុបដីត្រូវមានការពិនិត្យនិងអនុញ្ញាតពី **អ.ជ.ស.ព.**
- ត្រួតពិនិត្យនិងគ្រប់គ្រងរាល់សកម្មភាពនានាដែលអាចបណ្ដាលឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ស្ថានីយបុរាណ។

**មាត្រា៨ .–**

ក្នុងករណីសិក្សាស្រាវជ្រាវឬប្រទះឃើញដោយចៃដន្យនូវរចនាសម្ព័ន្ធប្រាសាទ ដូចជា៖ ខឿនប្រាសាទ តួប្រាសាទ កសិណ ស្រះបុរាណ បារាយណ៍ ស្ពាន ផ្លូវបុរាណ ជាដើម នៅក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក ទោះស្ថិតក្នុងតំបន់ណាក៏ដោយ ត្រូវបានកំណត់ចម្ងាយបរិវេណជុំវិញនោះតាមទំហំនិងស្ថានភាពជាក់ស្តែង និងត្រូវការពារដូចតំបន់ស្នូលដែរ។

## ផ្នែកទី២

## ការគ្រប់គ្រងទេសចរនិងអ្នកស្រាវជ្រាវ

**មាត្រា៩ .–**

ការគ្រប់គ្រងទេសចរនិងអ្នកស្រាវជ្រាវនៅរមណីយដ្ឋានវប្បធម៌ក្នុងតំបន់ទាំង៣ **អ.ជ.ស.ព.** ត្រូវ៖

- គ្រប់គ្រងការចេញ ចូលរបស់ទេសចរ អ្នកស្រាវជ្រាវ និងសាធារណជន
- រៀបចំផែនការសកម្មភាពនិងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងសេវាកម្មទេសចរណ៍ ខ្សែទស្សនាចរ កម្មវិធីវិនិយោគទេសចរណ៍
- កំណត់តម្លៃបណ្ណទស្សនា ដោយមានការពិភាក្សា ឯកភាពជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់រាល់តម្លៃសេវាកម្មពាណិជ្ជកម្មដូចជា ថតផ្សាយពាណិជ្ជកម្ម ពិធីជប់លៀង ពិធីសម្តែងសិល្បៈទស្សនីយភាព ថតខ្សែភាពយន្ត សេវាកម្មដឹកជញ្ជូន និងសេវាកម្មផ្សេងៗទៀត
- ទប់ស្កាត់រាល់សកម្មភាពបង្កផលប៉ះពាល់ដល់តម្លៃរមណីយដ្ឋាននិងបរិស្ថានដែលបណ្តាលមកពីទេសចរ និងអ្នកស្រាវជ្រាវ រួមទាំងសាធារណជនទូទៅ
- បន្ថយផលប៉ះពាល់អវិជ្ជមានបណ្តាលមកពីទេសចរទៅលើសហគមន៍
- ពិនិត្យនិងឯកភាពលើការបោះពុម្ពផ្សាយរាល់លទ្ធផលនៃការសិក្សាស្រាវជ្រាវ បុរាណវិទ្យា ជាតិពន្ធុវិទ្យា ស្ថាបត្យកម្ម និងនគរូបនីយកម្ម ដោយអ្នកវិទ្យាសាស្ត្រ ហើយត្រូវរក្សាជាសិទ្ធិបេតិកភណ្ឌរបស់អ្នកស្រាវជ្រាវក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ។ ក្រោយផុតអាជ្ញាយុកាលនៃសិទ្ធិបេតិកភណ្ឌនេះ លទ្ធផលនៃការសិក្សាស្រាវជ្រាវ និងការបោះពុម្ពផ្សាយត្រូវរក្សាទុកជាកម្មសិទ្ធិរបស់ **អ.ជ.ស.ព.** សម្រាប់ប្រើប្រាស់ក្នុងផលប្រយោជន៍សាធារណៈ។

**មាត្រា១០ .–**

ការគ្រប់គ្រងទេសចរក្នុងតំបន់ស្នូល **អ.ជ.ស.ព.** ត្រូវ៖

- ហាមជក់បារីនៅក្នុងតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រនិងទប់ស្កាត់រាល់សកម្មភាពដែលបង្កឲ្យមានអគ្គិភ័យ
- កំណត់និងរៀបចំខ្សែទស្សនាតាមបែបបទ
- ដាក់ឱ្យមានជាប្រចាំនូវមន្ត្រីរបស់ **អ.ជ.ស.ព.** ដើម្បីផ្តល់ព័ត៌មានណែនាំ ថែរក្សាសន្តិសុខ គុណភាពបរិស្ថាន និងផ្តល់សេវាផ្សេងៗដល់ទេសចរ និងសាធារណជន
- កម្រិតចំនួនភ្ញៀវទេសចរដែលចូលទស្សនានៅតាមទីតាំងប្រាសាទនីមួយៗ ដើម្បីរក្សាគុណភាព ទស្សនកិច្ចនិងការការពារ

- កំណត់ប្រភេទនិងល្បឿនយានយន្តដែលត្រូវអនុញ្ញាតឱ្យចេញ ចូលក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក។

**មាត្រា១១ .-**

ការគ្រប់គ្រងទេសចរក្នុងតំបន់ទ្រនាប់ **អ.ជ.ស.ព.** ត្រូវ៖

- ពិនិត្យនិងកម្រិតល្បឿនបើកបរ ចេញ ចូលយានយន្តគ្រប់ប្រភេទ មិនអនុញ្ញាតឱ្យរថយន្តដឹកជញ្ជូនធុនធ្ងន់ឆ្លងកាត់ និងតម្រូវឱ្យយានយន្តទាំងនោះទៅចតនៅចំណតយានជំនិះ
- កំណត់ទីតាំងទទួលភ្ញៀវទេសចរនិងចំណតយានជំនិះ
- កសាងហេដ្ឋារចនាសម្ព័ន្ធនិងបង្កើតសេវាសម្រាប់បម្រើឱ្យការអភិរក្សនិងការអភិវឌ្ឍទេសចរណ៍នៅក្នុងតំបន់រមណីយដ្ឋាន។

## ផ្នែកទី៣
## សំណង់ទេសចរណ៍

**មាត្រា១២ .-**

រាល់ការសាងសង់សំណង់ទេសចរណ៍នៅរមណីយដ្ឋានសំបូរព្រៃគុកក្នុងតំបន់ទាំង៣ ត្រូវមានការអនុញ្ញាតពី **អ.ជ.ស.ព.** ។

**មាត្រា១៣ .-**

រាល់សំណង់ទេសចរណ៍ក្នុងតំបន់ស្នូល **អ.ជ.ស.ព.** ត្រូវ៖

- អនុញ្ញាតឱ្យមានសំណង់តិចបំផុតសម្រាប់បម្រើសេវាទេសចរណ៍ដូចជា តូបលក់អាហារនិងភេសជ្ជៈ ផ្លូវថ្មើរជើង បង្គន់អនាម័យ កន្លែងរង់ចាំ កន្លែងសង្គ្រោះបឋម កន្លែងផ្តល់ព័ត៌មានស្រាវជ្រាវ និងអភិរក្ស។ សំណង់ទាំងនោះ ជាប្រភេទសំណង់ស្រាល និងត្រូវបន្សុីជាមួយបរិស្ថាន
- កំណត់ទីកន្លែងនិងរៀបចំចំណតរង់ចាំឱ្យតិចបំផុត
- រៀបចំកន្លែងសម្រាប់ភ្ញៀវទេសចរនិងសាធារណជនបានទស្សនាក្នុងទីតាំងកំណាយបុរាណវិទ្យា និងការងារជួសជុលប្រាសាទដែលកំពុងអនុវត្ត។

**មាត្រា១៤ .-**

ក្នុងតំបន់ទ្រនាប់និងតំបន់រណប **អ.ជ.ស.ព.** ត្រូវ៖

- កំណត់ទីកន្លែងដាក់លាក់និងរៀបចំឱ្យមានចំណតយានជំនិះ
- រៀបចំទីកន្លែងមណ្ឌលសិប្បកម្មតូចៗ ដើម្បីផ្តល់លទ្ធភាពផ្នែកសេដ្ឋកិច្ចដល់អ្នករស់នៅទីនោះ
- លើកទឹកចិត្តឱ្យមានការសាងសង់សំណង់ សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាជនក្នុងសហគមន៍មូលដ្ឋានឱ្យមានមុខជំនាញក្នុងផ្នែកទេសចរណ៍ កសិកម្ម បរិស្ថាន សិប្បកម្ម និងឧស្សាហកម្មខ្នាតតូច ដោយធានាឱ្យបាននូវសេវាកម្មសមរម្យ។

## ផ្នែកទី៤
## រមណីយដ្ឋានវប្បធម៌

**មាត្រា១៥ .-**

រមណីយដ្ឋានវប្បធម៌ក្នុងតំបន់ទាំង៣ **អ.ជ.ស.ព.** ត្រូវ៖

- រៀបចំផែនការដើម្បីបង្ហាញសក្ដានុពលបុរាណវិទ្យា ជាតិពន្ធុវិទ្យា ស្ថាបត្យកម្ម ព្រមទាំងទេសភាពវប្បធម៌ និងប្រពៃណីអ្នកស្រុកក្នុងតំបន់
- រៀបចំឲ្យមានកន្លែងផ្ដល់ព័ត៌មាននៅតាមតំបន់នីមួយៗនិងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ បង្កើតកន្លែងផ្ដល់ព័ត៌មាននៅក្រៅរមណីយដ្ឋានការពារ ដើម្បីផ្ដល់ជូនទេសចរនិងសាធារណជននូវការណែនាំស្ដីពីបេតិកភណ្ឌប្រាសាទសំបូរព្រៃគុក។

**មាត្រា១៦ .-**

ក្នុងតំបន់ស្នូលនិងតំបន់ទ្រនាប់ **អ.ជ.ស.ព.** ត្រូវរៀបចំឱ្យមានមគ្គុទ្ទេសក៍ និងដាក់ផ្លាកសញ្ញាបង្ហាញពីរមណីយដ្ឋានដែលមានលក្ខណៈដោយឡែកដូចជា ក្រុមប្រាសាទសំខាន់ទាំងបី (ប្រាសាទសំបូរ ប្រាសាទយាយពន្ធ និងប្រាសាទតោ) ក្រុមប្រាសាទរបងរមាស និងប្រាសាទរណបផ្សេងៗទៀត ព្រមទាំងរចនាសម្ព័ន្ធក្រុងបុរាណ។

**មាត្រា១៧ .-**

**អ.ជ.ស.ព.** អាចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំបង្កើតកម្មវិធីបង្ហាញដល់សិស្សនិស្សិត និងទេសចរ ស្ដីពីជីវភាពរស់នៅរបស់ប្រជាជន តាមរយៈទស្សនីយភាព របាំបុរាណ ប្រពៃណីទំនៀមទម្លាប់ ផលិតកម្ម សិប្បកម្ម និងទិដ្ឋភាពពិសេសៗរបស់រមណីយដ្ឋានសំបូរព្រៃគុក។

## ផ្នែកទី៥
## ការគ្រប់គ្រងធនធានធម្មជាតិ

**មាត្រា១៨ .-**

ការគ្រប់គ្រងទេសភាពនៅរមណីយដ្ឋានក្នុងតំបន់ទាំង៣ **អ.ជ.ស.ព.** ត្រូវ៖

- គ្រប់គ្រងទឹក ព្រៃឈើ និងសត្វព្រៃ ដើម្បីថែរក្សា ការពារប្រព័ន្ធអេកូឡូស៊ី និងបង្កើនជីវៈចម្រុះ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ការពារនិងបង្កើនតម្លៃទេសភាពធម្មជាតិនិងវប្បធម៌
- បញ្ចូលទៅក្នុងផែនការនិងសកម្មភាពនៃការចាត់ចែងគ្រប់គ្រងរមណីយដ្ឋាននូវគោលនយោបាយ និងទិសដៅសម្រាប់ចាត់ចែងគ្រប់គ្រងទេសភាព
- ហាមដាច់ខាត់រាល់ការផ្សាយពាណិជ្ជកម្មគ្រប់រូបភាពក្នុងតំបន់ស្នូលនិងតំបន់ទ្រនាប់។

**មាត្រា១៩ .-**

ក្នុងតំបន់ស្នូល **អ.ជ.ស.ព.** ត្រូវ៖

- ថែរក្សាទឹក ដីព្រៃឈើ ព្រមទាំងដាំឡើងវិញនូវព្រៃឈើធម្មជាតិ
- ថែទាំ ដាំដើមឈើនៅជុំវិញប្រាសាទ និងយកចេញដើមឈើដែលប៉ះពាល់ដល់សោភណភាព ឬអាចបំផ្លាញដល់រចនាសម្ព័ន្ធសំណង់បុរាណ
- រៀបចំបង្ហាញសភាពដើមពិតនៃបុរាណវិទ្យា ដោយរៀបចំទេសភាពឱ្យមានលក្ខណៈសមស្រប តាមបុរាណវិទ្យា

- ចាត់ចែងរៀបចំទេសភាពនៅជុំវិញប្រាសាទ តាមប្លង់គោលនៃគម្រោងរៀបចំអភិរក្សនិងអភិវឌ្ឍតំបន់មានប្រាសាទ។

**មាត្រា២០ .-**

ក្នុងតំបន់ទ្រនាប់និងតំបន់ណេប **អ.ជ.ស.ព.** ត្រូវ៖

- បង្កើនសួនរុក្ខជាតិនិងផ្លូវលំតាមដងព្រៃ
- អនុវត្តកម្មវិធីដាំដើមឈើ ដែលមានពូជនៅក្នុងតំបន់
- រក្សានិងបង្កើតឱ្យមានតំបន់ព្រៃទ្រនាប់ ដោយរៀបចំដាំដើមឈើឡើងវិញ
- ការពារលើកស្ទួយតម្លៃទេសភាពតាមរយៈការបង្កើតសកម្មភាព បរិស្ថាន កសិកម្ម និងការរៀបចំដែនដី។

**មាត្រា២១ .-**

ការចាត់ចែងទឹកនៅរមណីយដ្ឋានក្នុងតំបន់ការពារទាំង៣ **អ.ជ.ស.ព.** ត្រូវ៖

- ជួសជុលកែលម្អដោយផ្នែកៗនូវរចនាសម្ព័ន្ធធារាសាស្ត្របុរាណនិងចាត់ចែងរបបគ្រប់គ្រងទឹកតាមសំណង់ធារាសាស្ត្រថ្មី ឱ្យមានប្រសិទ្ធភាព
- ជៀសវាងការប្រើបច្ចេកវិទ្យានិងរចនាសម្ព័ន្ធថ្មីដែលអាចធ្វើឱ្យប៉ះពាល់ដល់សំណល់បុរាណ។

**មាត្រា២២ .-**

ក្នុងតំបន់ទាំង៣ **អ.ជ.ស.ព.** ត្រូវ៖

- ថែរក្សាប្រព័ន្ធធារាសាស្ត្របុរាណដែលមានស្រាប់និងបរិស្ថានជុំវិញ
- សិក្សានិងរកលទ្ធភាពក្នុងការស្តារដើម្បីឱ្យដំណើរការឡើងវិញនូវប្រព័ន្ធធារាសាស្ត្របុរាណ
- លើកគម្រោងផែនការស្តារប្រព័ន្ធធារាសាស្ត្រតូចៗ សម្រាប់បម្រើឱ្យការអភិវឌ្ឍកសិទេសចរណ៍ និងរក្សាលំនឹងនិងការប្រែប្រួលអាកាសធាតុ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរដែនដីក្នុងករណីចាំបាច់។

**មាត្រា២៣ .-**

ក្នុងតំបន់ណេប **អ.ជ.ស.ព.** អាចអនុញ្ញាតឱ្យអភិវឌ្ឍធារាសាស្ត្រតូចៗ ដើម្បីបង្កើនផលិតផលកសិកម្មនិងការប្រើប្រាស់ផ្ទាល់របស់អ្នករស់នៅទីនោះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថាននិងបុរាណវត្ថុ។

## ជំពូកទី៦

## ប្រជាជន

**មាត្រា២៤ .-**

**អ.ជ.ស.ព.** ត្រូវ៖

- ផ្តល់អាទិភាពការងារដល់ប្រជាជនក្នុងរមណីយដ្ឋាន ដើម្បីចូលរួមចំណែកថែរក្សានិងលើកតម្លៃរមណីយដ្ឋាន
- តាមដានការប្រែប្រួលនៃកំណើននិងកម្រិតជីវភាពរស់នៅរបស់ប្រជាជន ដើម្បីបង្កើនការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាជននៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

**មាត្រា២៥ .-**

កែលម្អផ្លូវចេញ ចូលសម្រាប់អ្នករស់នៅក្នុងតំបន់នោះ ដោយជៀសវាងការប៉ះពាល់រមណីយដ្ឋាន។

**មាត្រា២៦ .-**

ក្នុងតំបន់ស្នូល **អ.ជ.ស.ព.** មិនត្រូវអនុញ្ញាតឱ្យមានការបង្កើតនិងពង្រីកភូមិ ព្រមទាំងទីប្រជុំជន។

**មាត្រា២៧ .-**

ក្នុងតំបន់ទ្រនាប់៖

- រក្សាទុកភូមិបុរាណ
- មិនត្រូវអនុញ្ញាតឱ្យមានការបង្កើតនិងពង្រីកភូមិ ព្រមទាំងទីប្រជុំជន
- ផ្តល់អាទិភាពដល់អ្នករស់នៅក្នុងរមណីយដ្ឋានដោយឱ្យច្បាប់អនុញ្ញាតប្រកបមុខរបរតូចតាចជាលក្ខណៈគ្រួសារ
- បង្កលក្ខណៈងាយស្រួល ជួយជំរុញ និងលើកទឹកចិត្តដល់ប្រជាជនឱ្យបង្កបង្កើនផលកសិកម្ម ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងបង្កើតមុខរបរ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ។

**មាត្រា២៨ .-**

ក្នុងតំបន់រណប **អ.ជ.ស.ព.** ត្រូវរក្សាទុកមុខរបរនិងការប្រើប្រាស់តាមប្រពៃណីនូវដីដាំដុះ វាលស្មៅ ត្រពាំង និងបឹងបួ។

## ផ្នែកទី៧
## វត្តអារាម

**មាត្រា២៩ .-**

ក្នុងតំបន់ស្នូលនិងតំបន់ទ្រនាប់ **អ.ជ.ស.ព.** ត្រូវ៖

- រក្សាទុកសហគមន៍សាសនាដែលមាន ហើយថែទាំវត្តអារាមចាស់ៗ
- ហាមកសាងវត្តថ្មីឬទីតាំងសាសនាផ្សេងៗ ក្រៅពីសំណង់ដែលមានស្រាប់។

**មាត្រា៣០ .-**

ក្នុងតំបន់រណប ការបង្កើតវត្តថ្មីនៅតាមភូមិនានា ត្រូវគោរពតាមបទប្បញ្ញត្តិច្បាប់។

## ផ្នែកទី៨
## សិប្បកម្មនិងសេវាកម្ម

**មាត្រា៣១ .-**

**អ.ជ.ស.ព.** មិនអនុញ្ញាតឱ្យមានការអភិវឌ្ឍផ្សេងៗក្នុងតំបន់ស្នូល លើកលែងតែសិប្បកម្មនិងសេវាកម្មទ្រង់ទ្រាយតូចៗដែលមានលក្ខណៈប្រពៃណី បម្រើឱ្យការអភិរក្សកសិកម្មនិងទេសចរណ៍របស់ប្រជាជនដែលមានទីលំនៅស្រាប់នៅក្នុងតំបន់នោះ។

**អ.ជ.ស.ព.** ត្រូវគ្រប់គ្រងឱ្យបានត្រឹមត្រូវរាល់សំណល់រឹងនិងរាវបង្កើតឡើងដោយសិប្បកម្មនិងសេវាកម្ម។/.

**មាត្រា៣២ .-**

ក្នុងតំបន់ស្នូលនិងតំបន់ទ្រនាប់ **អ.ជ.ស.ព.** ត្រូវកំណត់ទីតាំង ទំហំ និងចំនួនតូបលក់វត្ថុទាំងឡាយឱ្យមានគុណភាពនិងរក្សាតម្លៃរមណីយដ្ឋាន។

**មាត្រា៣៣ .-**

ក្នុងតំបន់ទ្រនាប់និងតំបន់រណប **អ.ជ.ស.ព.** ត្រូវ៖

- ជំរុញបង្កើនរោងសិប្បកម្មនៅក្នុងភូមិដែលមានស្រាប់ឬក្នុងមណ្ឌលទទួលទេសចរ
- ជំរុញសិប្បកម្មតូចៗនិងការផលិតវត្ថុអនុស្សាវរីយ៍។

## ផ្នែកទី៩

## បណ្តាញចរន្តអគ្គិសនី

**មាត្រា៣៤ .-**

ក្នុងតំបន់ទាំង៣ **អ.ជ.ស.ព.** ត្រូវ៖

- អនុញ្ញាតឱ្យដាក់បណ្តាញចរន្តអគ្គិសនី ដែលផ្តល់ដល់មូលដ្ឋាននោះ ដោយរក្សាសោភណភាពរមណីយដ្ឋាន
- គ្រប់គ្រងរាល់ការតុបតែងភ្លើងបំភ្លឺនិងការរៀបចំពិធីផ្សេងៗក្នុងរមណីយដ្ឋាន ដោយត្រូវអនុវត្តតាមលក្ខណៈបច្ចេកទេស។

## ផ្នែកទី១០

## ការទាក់ទាញអារម្មណ៍ចំពោះបរិស្ថាន

**មាត្រា៣៥ .-**

ក្នុងតំបន់ទាំង៣ **អ.ជ.ស.ព.** ត្រូវផ្តើមអនុវត្តកម្មវិធី ដើម្បីឱ្យមានការទាក់ទាញអារម្មណ៍ប្រជាជនមូលដ្ឋាន និងទស្សនិកជនចំពោះសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ និងចំពោះបញ្ហាបរិស្ថាន។

**មាត្រា៣៦ .-**

ក្នុងតំបន់ស្នូល **អ.ជ.ស.ព.** ត្រូវ៖

- កំណត់ទីតាំងនិងរៀបចំតូបលក់វត្ថុអនុស្សាវរីយ៍តាមរចនាបថខ្មែរ
- កំណត់ទីតាំងនិងរៀបចំឱ្យមានបង្គន់អនាម័យ ធុងសម្រាមឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

## ផ្នែកទី១១

## ការបណ្តុះបណ្តាលធនធានមនុស្ស

**មាត្រា៣៧ .-**

**អ.ជ.ស.ព.** ត្រូវ៖

- បណ្តុះបណ្តាលអ្នកជំនាញសម្រាប់ការដ្ឋានកំណាយនិងការងារអភិរក្ស
- សហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរ ឆ្មាំរមណីយដ្ឋាន បុគ្គលិកថែទាំ/

- សហការជាមួយស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ដើម្បីបណ្តុះបណ្តាលមន្ត្រីជំនាញគ្រប់កម្រិត
- ផ្តល់កិច្ចសហប្រតិបត្តិការជាមួយបុរាណវិទូ ស្ថាបត្យករ អ្នកអភិរក្ស និងអ្នកប្រកបវិជ្ជាជីវៈផ្សេងៗទៀតក្នុងផ្នែកចាត់ចែងនិងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌
- យកចិត្តទុកដាក់ដល់ប្រជាជនក្នុងតំបន់ដើម្បីរក្សានិរន្តរភាពក្នុងការការពារនិងការអភិវឌ្ឍ
- លើកទឹកចិត្តនិងបណ្តុះបណ្តាលប្រជាជនឱ្យមានមុខជំនាញទូទៅ ក្នុងផ្នែកកសិកម្ម បរិស្ថាន និងទេសចរណ៍។

## ផ្នែកទី១២
## ការអភិវឌ្ឍ

**មាត្រា៣៨ .-**

រាល់កិច្ចអភិវឌ្ឍរមណីយដ្ឋានសំបូរព្រៃគុកក្នុងតំបន់ទាំង៣ **អ.ជ.ស.ព.** ត្រូវ៖

- រៀបចំនីតិក្រមសម្រាប់ពិនិត្យនិងអនុម័តគម្រោងអភិវឌ្ឍនៅក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក
- រាល់គម្រោងអភិវឌ្ឍត្រូវគិតគូរពីផលប៉ះពាល់ សម្បត្តិវប្បធម៌ បរិស្ថានធម្មជាតិ និងសង្គមឲ្យនៅកម្រិតទាបបំផុត
- ធ្វើកំណាយបុរាណវិទ្យាដើម្បីប្រមូលទិន្នន័យសម្រាប់សិក្សាវិភាគនិងចងក្រងឯកសារ មុននឹងចាប់ផ្តើមដំណើរការអភិវឌ្ឍ។

**មាត្រា៣៩ .-**

ការអភិវឌ្ឍក្នុងតំបន់ស្នូលត្រូវហាមឃាត់ លើកលែងតែការអភិវឌ្ឍណាដែលមានសារប្រយោជន៍សម្រាប់ការអភិរក្ស និងការលើកតម្លៃនៃរមណីយដ្ឋានសំបូរព្រៃគុក ដែលធ្វើឡើងដោយ **អ.ជ.ស.ព.**។

ការអភិវឌ្ឍក្នុងតំបន់ទ្រនាប់ ត្រូវហាមឃាត់ លើកលែងតែការអភិវឌ្ឍណាដែលមានសារប្រយោជន៍សម្រាប់អភិរក្ស ទេសចរណ៍ និងការលើកតម្លៃរមណីយដ្ឋានបុរាណឬសម្រាប់ថែរក្សាទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជននៅតំបន់នោះ។

ការអភិវឌ្ឍក្នុងតំបន់ណោប **អ.ជ.ស.ព.** ត្រូវកំណត់ប្លង់គោលនិងប្លង់ប្រើប្រាស់ដីធ្លីឱ្យស្របតាមបទដ្ឋានបច្ចេកទេសនិងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាត្រា៤០ .-**

រាល់ការសាងសង់សំណង់ក្នុងតំបន់រមណីយដ្ឋានសំបូរព្រៃគុក ត្រូវមានលិខិតអនុញ្ញាតសាងសង់ពី **អ.ជ.ស.ព.** និងត្រូវគោរពតាមបទប្បញ្ញត្តិនគរូបនីយកម្មនិងសំណង់ជាធរមាន។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៤១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។/.

**មាត្រា៤២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៧



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ភឿង សកុណា**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ